# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីពុទ្ធភាសិតមួយបទពោលថា កម្មតែងចែកសត្វឲ្យថោកទាបនិងខ្ពង់ខ្ពស់

web site: hoksavann.org

ថ្ងៃទី១៣ សីហា ២០០៦

ពាក្យថា កម្មតែងចែកសត្វទាំងឡាយឲ្យថោកទាបនិងខ្ពង់ខ្ពស់ ចេញពីពុទ្ធភាសិតថា កម្មំ សត្តេ វិភជ្ជតិ ហីនប្បណីតតាយ ។ កម្មក្នុងន័យព្រះពុទ្ធសាសនា សំដៅយកអំពើប្រកបដោយចេតនា ដូចពុទ្ធភាសិតមួយបទទៀតពោលថា ចេតនា ហំ ភិក្ខវ កម្មំ ទោមិ ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនាជាតួកម្ម ។ បើធ្វើតាមផ្លូវកាយហៅថាកាយកម្ម, តាមផ្លូវវាចាហៅថាវចីកម្ម, តាមផ្លូវចិត្តហៅថាមនោកម្ម ។ ចេតនាជាតួចេតសិកធម៌ គឺជាសកម្មភាពរបស់ចិត្តដែលប្រព្រឹត្តនៅក្នុងអារម្មណ៍ ។ មួយទៀតពាក្យថា ចេតនា គឺជាអំពើប្រកបដោយចិត្តក្លែង ហៅថាសចិត្តក: ។ អំពើដែលពុំមានចិត្តនិងចេតសិកប្រកបជាមួយទេ ពុំឈ្មោះថាកម្មក្នុងព្រះពុទ្ធសាសនាឡើយ ។ អំពើនោះមានពីរយ៉ាងគឺ អំពើល្អ ហៅថាកុសលកម្ម អំពើអាក្រក់ហៅថា អកុសលកម្ម ។

អំពើល្អនិងអំពើអាក្រក់នោះ ចេញមកពីសកម្មភាពខ្លួនឯង បាលីថា កម្មស្សកោម្ហិ ប្រែថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន ។ ព្រះពុទ្ធត្រាស់ដឹងទ្រឹស្តីកម្មផលថា សេចក្តីសុខទុក្ខចំរើនវិនាសកើតចេញមកអំពីអំពើរបស់ខ្លួន ហើយព្រះអង្គសំដែងប្រាប់មនុស្សសត្វទាំងអស់គ្នា ជ្រើសរើសផ្លូវប្រតិបត្តិដោយខ្លួនឯង បាលីថា អក្ខាតារោតថាគតោ ។ ពុទ្ធភាសិតមួយបទទៀតពោលថា កម្មុនា វត្តតី លោកោ ប្រែថា សត្វទាំងឡាយប្រព្រឹត្តទៅតាមអំពើរបស់ខ្លួន ។ បានសេចក្តីថាជីវិតរបស់ខ្លួនប្រព្រឹត្តទៅយ៉ាងណា ស្រេចនៅលើសកម្មភាពល្អអាក្រក់របស់ខ្លួន ជាអ្នកចាត់ចែង ។ ពាក្យកម្មនេះបើតាមន័យរបស់ភាសាខ្មែររេន័យថា ការលំបាកឬការរងទុក្ខ ។ តាមន័យពិត កម្មនេះជាឈ្មោះអំពើ ជាពាក្យកណ្តាល មានទាំងអំពើល្អនិងអំពើអាក្រក់ ។ អំពើល្អផលជាសុខ អំពើអាក្រក់ឲ្យផលជាទុក្ខ ។ ប៉ុន្តែបើនិយាយឲ្យដល់ជំរៅព្រះពុទ្ធ

សាសនា ពាក្យខ្មែរថាកម្មដែលមានន័យថាទុក្ខនេះ ទៅជាត្រូវទៅវិញ ព្រោះកម្មល្អកម្មអាក្រក់នេះឯង នាំសត្វឲ្យមានជាតិ គឺបដិសន្ធិតទៅទៀត ។ ការមានជាតិ ជាហេតុនាំឲ្យមានទុក្ខ ។

ព្រះបរមគ្រូត្រាស់ថា ទំនាបនិងកំពស់របស់មនុស្ស ត្រូវស្ថិតនៅលើអំពើរបស់គេ ដែលហៅថាកម្មនេះឯង ពុំមែនស្ថិតនៅលើក្រមាន មានយសសក្តិឥតយសសក្តិឡើយ ។ បានសេចក្តីថា មនុស្សឧត្តមប្រសើរនិងមនុស្សថោកទាប ពុំមែនយកជាតិត្រកូល ទ្រព្យសម្បត្តិ យសសក្តិ ធ្វើជាខ្នាតសំរាប់វាស់ឡើយ ។ ស្ទើរតែគ្រប់ទំព័រនៃគម្ពីរព្រះត្រៃបិដក ដែលជាគម្ពីរដ៏ធំរបស់ព្រះពុទ្ធសាសនា ព្រះអង្គបានយកកម្មផលនេះធ្វើជាខ្នាត ។ ព្រះសមណគោតមជាគ្រូនៃទេវតានិងមនុស្សទាំងឡាយបានពន្យល់ថា បើអ្នកនោះមានជាតិត្រកូលខ្ពស់ មានទ្រព្យសម្បត្តិច្រើន មានអំណាចបុ-ណ្យសក្តិធំ តែជាអ្នកប្រព្រឹត្តធ្វើអំពើអាក្រក់ ដោយកាយដោយវាចានិងដោយចិត្ត អ្នកនោះចាត់ទុកថា ជាមនុស្សថោកទាប ។ ផ្ទុយទៅវិញ បើមនុស្សនោះ ដែលគេចាត់ថា កើតក្នុងត្រកូលថោកទាប ជាអ្នកក្រគ្មានបុណ្យសក្តិ តែជាមនុស្សប្រព្រឹត្តធ្វើអំពើល្អ ដោយកាយដោយវាចានិងដោយចិត្ត មនុស្សនោះចាត់ថាជាមនុស្សខ្ពង់ខ្ពស់ ។ មួយទៀតអ្នកមានវិជ្ជាផ្លូវលោកខ្ពង់ខ្ពស់ តែប្រព្រឹត្តអំពើអាក្រក់ ដោយកាយវាចាចិត្តក៏ចាត់ថាជាមនុស្សថោកទាប ។ ផ្ទុយទៅវិញអ្នកនោះ គ្មានវិជ្ជាជ្រៅជ្រះនឹងគេទេ ប៉ុន្តែជាអ្នកប្រព្រឹត្តធ្វើអំពើល្អ លោកចាត់ទុកជាមនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ ។ បើអ្នកនោះមានវិជ្ជាខ្ពង់ខ្ពស់ ហើយប្រព្រឹត្តល្អទៀត ទើបជាមនុស្សខ្ពង់ខ្ពស់ ។ ដូច្នេះមនុស្សមានលក្ខណៈខុសគ្នា ដោយសារអំពើរបស់គេមានលក្ខណៈខុសគ្នា ។ ព្រះពុទ្ធបានចែកមនុស្សជាច្រើនប្រភេទទៅតាមអំពើដែលគេបានប្រព្រឹត្ត ជាមនុស្សពេញលក្ខណៈគឺជាមនុស្សមានធម៌ក្នុងខ្លួន ដោយហោចណាស់មានសីល៥ ។ មនុស្សបេត្តោ មនុស្សដូចជាប្រេត មនុស្សមានទ្រព្យសម្បត្តិតែកំណាញ់ស្វិតស្វាញ ។ មនុស្សតិរច្ឆា-នោ មនុស្សជាសត្វ មនុស្សមិនស្គាល់គុណ ។ មនុស្សនេរយិកោ មនុស្សដូចសត្វនរក ជាមនុស្សរំលោភសិទ្ធិអ្នកដទៃ ធ្វើបាបកាប់សម្លាប់អ្នកដទៃ ។ ដូច្នេះកម្មផលតែងបែងចែកមនុស្សសត្វ ឲ្យខ្ពង់ខ្ពស់និងថោកទាបដូចពោលមកនេះឯង ។៚

❑ ❑

❑